**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន នៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា១.-**

ត្រូវបានបង្កើតនាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន ចំណុះអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល ដើម្បីបំពេញបន្ថែមអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល។

**មាត្រា២.-**

នាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀនមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ជាសេនាធិការរបស់ក្រសួងសុខាភិបាលក្នុងកិច្ចការសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀន
- រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ សេចក្តីណែនាំជាតិស្តីពីសុខភាពផ្លូវចិត្ត និងឯកសារបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន សម្រាប់ដាក់ឲ្យអនុវត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាពអ្នកញៀនគ្រឿងញៀនឲ្យមានប្រសិទ្ធភាព
- គ្រប់គ្រងទិន្នន័យស្តីពីសុខភាពផ្លូវចិត្ត និងសុខភាពអ្នកញៀនគ្រឿងញៀន ព្រមទាំងអភិបាលត្រួតពិនិត្យ តាមដាន វាយតម្លៃអំពីវឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តសកម្មភាពរបស់ខ្លួនសម្រាប់ពង្រឹងនិងពង្រីកសេវាសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀននៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងតាមសហគមន៍ប្រកបដោយគុណភាពគ្រប់ជ្រុងជ្រោយ
- សិក្សាស្រាវជ្រាវស្តីពីសុខភាពផ្លូវចិត្តនិងបញ្ហាដែលពាក់ព័ន្ធដើម្បីឈានទៅបង្កើតនូវវិធីសាស្ត្រជឿនលឿនសម្រាប់បណ្តុះបណ្តាល ថែទាំ ព្យាបាល ការពារ លើកកម្ពស់ អប់រំ និងស្តារនីតិសម្បទា សុខភាពផ្លូវចិត្ត សង្គម រួមទាំងការប្រើប្រាស់ការបំពានគ្រឿងញៀន
- សម្របសម្រួលនិងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងគ្រឿងញៀន ក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍ សមាគមជាតិនិងអន្តរជាតិ និងជាមួយបណ្តាប្រទេសក្នុងតំបន់និងពិភពលោកលើការងារអភិវឌ្ឍវិស័យសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនព្រមទាំងវិស័យដទៃទៀតដែលពាក់ព័ន្ធ
- បណ្តុះបណ្តាលធនធានមនុស្សគ្រប់កម្រិតលើជំនាញសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលរបស់ក្រសួងសុខាភិបាលនិងស្ថាប័នពាក់ព័ន្ធដទៃទៀតទាំងសាធារណៈ ទាំងឯកជន
- ចាត់តាំងរៀបចំព្រឹត្តិការណ៍ផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀនជាលក្ខណៈជាតិនិងអន្តរជាតិ។

**មាត្រា៣.-**

នាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀនដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានសុខភាពផ្លូវចិត្តនិងការបំពានគ្រឿងញៀនត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ